ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE
អគ្គិសនីកម្ពុជា
លេខ : ០៥០១ អកក/ល.សកក.០៦

# សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក ចំនួន ០៦ រូប ដើម្បីចូលបម្រើការងារនៅ ការិយាល័យបុគ្គលិក នៃនាយកដ្ឋានរដ្ឋបាល ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

- បេក្ខជនភេទប្រុស, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ

១- សម្រាប់ បរិញ្ញាបត្រព័ត៌មានវិទ្យា ០២ រូប :

- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.II.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90% = ១,២៧៧,៣៧០ រៀល ឡើងទៅ
- កម្រិតជំនាញ : ចាប់ពី បរិញ្ញាបត្រព័ត៌មានវិទ្យា ឡើងទៅ (មានជំនាញខាង Programmer ឬ Database Developer)
- ភាសាអង់គ្លេស : ចេះ អាចប្រើការបានល្អ

២- សម្រាប់ បរិញ្ញាបត្រនីតិសាស្ត្រ ០១ រូប :

- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.II.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90% = ១,២៧៧,៣៧០ រៀល ឡើងទៅ
- កម្រិតជំនាញ : ចាប់ពី បរិញ្ញាបត្រនីតិសាស្ត្រ ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបានល្អ

៣-សម្រាប់ បរិញ្ញាបត្រ សេដ្ឋកិច្ច ឬ រដ្ឋបាលសាធារណៈ ឬ គ្រប់គ្រង ០៣ រូប :

- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.II.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90% = ១,២៧៧,៣៧០ រៀល ឡើងទៅ
- កម្រិតជំនាញ : ចាប់ពី បរិញ្ញាបត្រ សេដ្ឋកិច្ច ឬ រដ្ឋបាលសាធារណៈ ឬ គ្រប់គ្រង ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបានល្អ ។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រ៊ី(១.០០០ រៀល) ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចយក សៀវភៅគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ(ច្បាប់ចម្លង មានបញ្ជាក់ពី សាលារាជធានីភ្នំពេញ ឬសាលាខេត្ត) ឬលិខិតបញ្ជាក់ទីលំនៅ ចុះហត្ថលេខាពីខណ្ឌ-ស្រុក ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមារយាទ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)ចំនួន ០១ ច្បាប់

- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត ចំនួន ០១ ច្បាប់
- តារាងពិន្ទុ (TRANSCRIPT) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) ចំនួន ០១ ច្បាប់

*- **ទីកន្លែងទទួលពាក្យ** : សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់ អគ្គិសនីកម្ពុជា ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល នៃទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**អេង_គន្ធា**